# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៦

## អង្គការសង្គមស៊ីវិលសូមសម្តែងការមិនពេញចិត្តចំពោះការឃាត់ខ្លួន និងការរារាំងបុគ្គលិក និងអ្នកផលិតខ្សែវីដេអូ នៅខេត្តពោធិ៍សាត់

យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម នៅថ្ងៃនេះសូមសម្តែងការមិនពេញចិត្តចំពោះការឃាត់ និងការរារាំងប្រព្រឹត្តដោយមន្ត្រីស្រុក និងនគរបាលបរិស្ថានមកលើបុគ្គលិករបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") និងអ្នកផលិតខ្សែវីដេអូដែលអង្គការអាក់សិនអេតជួលនៅក្នុងឃុំថ្មដា ដែលបានកើតឡើងពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៦។

លោក ប៊ុត វណ្ណី ដែលជាបុគ្គលិករបស់ ម.ស.ម.ក និងលោក ផាន រៀម លោក រឿន បូរ៉ែន និងលោក សួង សុភ័ក្រ ដែលអ្នកទាំងបីជាអ្នកថតខ្សែវីដេអូឯកសាររបស់ក្រុមហ៊ុន វ៉ៃ ផ្លាស់ មីឌៀ (ដែលជួលដោយអង្គការអាក់សិនអេតកម្ពុជា) ត្រូវបាននគរបាលបរិស្ថានឃាត់រថយន្តនៅប្រហែលម៉ោង ១០ និង ៣០ នាទីព្រឹកថ្ងៃទី២៤ ខែធ្នូ ដោយហាមមិនឲ្យចេញពីភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ក្រុមការងារទាំងបួននាក់នេះបានធ្វើដំណើរទៅឃុំថ្មដា នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីថតយករូបភាពជាខ្សែអាត់វីដេអូ និងសម្ភាសអ្នកភូមិមួយចំនួន ដែលរងផលប៉ះពាល់ដោយបណ្តេញចេញដោយបង្ខំ ដោយសារគម្រោងអភិវឌ្ឍកសិឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស ដែលប្រតិបត្តិការដោយលោក ទ្រី ភាព ដែលជាឈ្មួញព្រៃឈើ។ ការថតជាខ្សែវីដេអូឯកសារជាសកម្មភាពនៃការអនុវត្តរួមគ្នានូវគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស រវាង ម.ស.ម.ក និងអង្គការអាក់សិនអេតកម្ពុជា ដែលមានគោលបំណងលើកកម្ពស់ការគោរពសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុនសាជីវកម្មទាំងឡាយដែលវិនិយោគលើវិស័យដីធ្លីនៅកម្ពុជា។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ លោក ប៊ុត វណ្ណី បានប្រឈមនឹងការគំរាមកំហែងមួយចំនួនពីអាជ្ញាធរមូលដ្ឋាន។ លោកអភិបាលស្រុកវាលវែងបានឲ្យមន្ត្រីមូលដ្ឋានមកហៅលោក វណ្ណី ឲ្យទៅជួបគាត់នៅការិយាល័យនៅថ្ងៃទី២៣ ខែធ្នូ ដើម្បីជជែកគ្នាពីវីដេអូឯកសារ។ នៅពេលដែលលោក វណ្ណី បដិសេធ នគរបាលមូលដ្ឋានក៏បានមករកគាត់ចំនួនពីរលើកទៀត ដើម្បីប្រាប់ថា លោកអភិបាលស្រុកចង់ជួបនៅថ្ងៃទី២៣ ខែធ្នូ។ ដោយមានការជួយសហការពីសហគមន៍មូលដ្ឋានផងនោះ ក្រុមការងារក៏បានបន្តការថតរបស់ខ្លួនទៀត។ ក៏ប៉ុន្តែ ចុងក្រោយ ក្រុមការងារត្រូវបង្ខំចិត្តឈប់ថត ដោយសារតែអាជ្ញាធរបានបិទផ្លូវ និងហាមមិនឲ្យថតនៅតំបន់ដីដែលមានជម្លោះនោះទៀត។

នៅព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៦ ក្រុមការងារក៏បានបន្តសកម្មភាពថតទៀត។ ទោះជាយ៉ាងនេះក្តី នៅប្រហែលម៉ោង ៩ និង ២០ នាទីព្រឹក ខណៈដែលក្រុមការងារត្រៀមចាកចេញ ក៏មាននគរបាលបរិស្ថានបានស្រែកថា នឹងមិនឲ្យក្រុមការងារទាំងនេះចាកចេញបានឡើយ។ ក្រុមការងារក៏បានដកថយមួយរយៈ ខណៈពេលនោះក៏មានសហគមន៍ជាច្រើនមកជួយគាំទ្រ។ យ៉ាងណាក្តី នៅប្រហែលម៉ោង ១០ និង ៣០ នាទី នគរបាលបរិស្ថានក៏បានបញ្ឈប់រថយន្តដែលក្រុមការងារជិះ នៅ

ពេលពួកគេព្យាយាមចាកចេញពីភូមិ ហើយក៏ឃាត់ក្រុមការងារទាំងនេះមួយរយៈពេលខ្លីនៅប៉ុស្តិ៍ត្រួតពិនិត្យ។ នៅប្រមាណជាម៉ោង ១១ ព្រឹក ក្រុមការងារអាចចាកចេញតាមរថយន្តរបស់ខ្លួន ដោយមានសហគមន៍ម្នាក់មកជាមួយផង។

នគរបាលបរិស្ថានពុំបានផ្តល់មូលហេតុសមស្របណាមួយក្នុងការរាំងសកម្មភាពដើរហើរ ឬការរឹតត្បិតលើសកម្មភាពរបស់ក្រុមការងារនោះទេ ហើយលោកអភិបាលស្រុកក៏មិនបានផ្តល់ហេតុផលអំពីការចង់ជួបបុគ្គលិករបស់ ម.ស.ម.ក នោះដែរ។

ហេតុការណ៍នៅថ្ងៃនេះបានកើតឡើងចំពេល ដែលមានការបង្ក្រាបកាន់តែខ្លាំងឡើងៗលើសេរីភាពមូលដ្ឋាននៅប៉ុន្មានឆ្នាំនេះ ហើយក៏ជាការបង្ហាញពីឧទាហរណ៍មួយទៀតនៃការកើនឡើងនូវការរឹតត្បិតហួសហេតុទៅលើលទ្ធភាពរបស់សង្គមស៊ីវិលនៅកម្ពុជាក្នុងការបំពេញការងាររបស់ខ្លួនដោយសេរី។ ការគំរាមកំហែង និងសកម្មភាពទាំងនេះហាក់ដូចជាការប៉ុនប៉ងយ៉ាងជាក់ស្តែងក្នុងការរាំងលើសកម្មភាពស្របច្បាប់របស់អង្គការសង្គមស៊ីវិលដើម្បីស្រាវជ្រាវ និងលើកកម្ពស់ការយល់ដឹងអំពីការបណ្តេញចេញដោយបង្ខំ និងការរំលោភដីធ្លីនៅក្នុងតំបន់ ព្រមទាំងយើងខ្ញុំសូមសម្តែងការមិនពេញចេញចំពោះការរំលោភបំពានលើសិទ្ធិសេរីភាពខាងសមាគម ការប្រមូលផ្តុំ និងការបញ្ចេញមតិរបស់អង្គការសង្គមស៊ីវិល និងសហគមន៍ពាក់ព័ន្ធ ក៏ដូចជា សិទ្ធិសេរីភាពក្នុងការដើរហើរ។ យើងខ្ញុំសូមអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធនៅមូលដ្ឋានទាំងអស់បញ្ឈប់ជាបន្ទាន់នូវការគំរាមកំហែង និងការយាយីទាំងឡាយមកលើសមាជិកសង្គមស៊ីវិល ក៏ដូចជាការប៉ុនប៉ងជ្រៀតជ្រែកមិនត្រឹមត្រូវទៅលើការងាររបស់សង្គមស៊ីវិល។

**អង្គការសង្គមស៊ីវិល ដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ រួមមាន ៖**

| ល.រ ឈ្មោះអង្គការសង្គមស៊ីវិល | ឈ្មោះអ្នកចូលរួម | លេខទំនាក់ទំនង |
|---|---|---|
| ១. អង្គការអោក់សិនអេតកម្ពុជា | អ្នកស្រី ហ៊ុន បូរមី | ០១២ ២០០ ៣៤១ |
| ២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | លោក ឌុច ពិសិដ្ឋ | ០១២ ៧១២ ៣៧១ |
| ៣. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ | | |
| ៤. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស | លោក មឿន តុលា | ០៩៣ ៥៥៦ ៦៤៣ |
| ៥. អង្គការសមធម៌កម្ពុជា | លោក អៀង វុទ្ធី | ០១២ ៧៩១ ៧០០ |
| ៦. Heinrich Böll Stiftung | លោក អាលី អាល់ណាហ្សារី | ០២៣ ២១០ ៥៣៥ |
| ៧. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន | លោក សៀ ភារម្យ | ០១២ ៨៥២ ៣២៥ |